ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំទិវានៃការចងចាំនៃដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការ ដើម្បីរៀបចំទិវានៃការចងចាំនៃដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | ទៀ បាញ់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២. ឯកឧត្តម | កៅ បាភ្នំ | ទីប្រឹក្សាផ្ទាល់ និងជានាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣. លោកជំទាវ | ឆាយ វ៉ាន់នឿន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤. ឯកឧត្តម | វង្សី វិស្សុត | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥. ឯកឧត្តម | អ៊ុក គឹមលេខ | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯកឧត្តម | អ៊ុង ស៊ាន | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |



www.pheakdeylaw.com

៧. ឯកឧត្តម សួង ហេង រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៨. ឯកឧត្តម ជុំច ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
៩. ឯកឧត្តម យូ ស៊ុនឡុង រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី សមាជិក
១០. នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១១. ឯកឧត្តម ឈិន កេតនា អគ្គលេខាធិការនៃគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក
១២. នាយឧត្តមសេនីយ៍ សំ វណ្ណថន អគ្គលេខាធិការ ក្រសួងការពារជាតិ សមាជិក
១៣. នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សា-នាយកខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ អគ្គនាយកនយោបាយ និងកិច្ចការបរទេស កពជ សមាជិកប្រចាំការ
១៤. ឯកឧត្តម គឹម គុណវឌ្ឍន៍ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សមាជិក
១៥. ឯកឧត្តម ប្រាជ្ញ ចន្ទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ សមាជិក
១៦. នាយឧត្តមសេនីយ៍ ជាំ វុទ្ធី អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១៧. ឧត្តមសេនីយ៍ឯក ជឿន សុវណ្ណថា មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី២ សមាជិក
១៨. ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការ បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម សមាជិក ។

គណៈកម្មការនេះ មានភារកិច្ចដឹកនាំចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំប្រារព្ធទិវានៃការចេងចាំនៃដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

**ប្រការ២.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន និងអនុគណៈកម្មការ របស់គណៈកម្មការរៀបចំទិវានៃការចេងចាំនៃដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលមានសមាសភាព និងភារកិច្ច ដូចខាងក្រោម ៖

**ក.លេខាធិការដ្ឋាន**

១. នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សា-នាយកខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ អគ្គនាយកនយោបាយ និងកិច្ចការបរទេស កពជ ប្រធាន
២. ឯកឧត្តម គឹម គុណវឌ្ឍន៍ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា អនុប្រធាន
៣. ឧត្តមសេនីយ៍ឯក ខៀវ ធេន ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ អនុប្រធាន
៤. ឧត្តមសេនីយ៍ឯក ប៉ាង ជារ៉ូ អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ សមាជិក
៥. ឯកឧត្តម អ៊ិត រឿន វីរៈវិចិត្រករ សមាជិក
៦. ឧត្តមសេនីយ៍ឯក មួង សុភា ទីប្រឹក្សាក្រសួងការពារជាតិ សមាជិក
៧. ឧត្តមសេនីយ៍ឯក ស៊ូ ស៊ុម អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស សមាជិក
៨. ឧត្តមសេនីយ៍ទោ សាយ សុវិទ្ធ នាយកវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា សមាជិក
៩. ឧត្តមសេនីយ៍ទោ វេង សុខហេង នាយករង នាយកដ្ឋានព័ត៌មាន កពជ សមាជិក ។

❖ លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ជាជំនួយការដល់គណៈកម្មការក្នុងការដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយអនុគណៈកម្មការ ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំបច្ចេកទេសនានា សម្រាប់គណៈកម្មការ
- កំណត់កម្មវិធីលម្អិតសកម្មភាពដំណើរការតាមទីតាំង និងពេលវេលាជាក់ស្តែង
- កំណត់កាលបរិច្ឆេទ និងទីតាំងដែលត្រូវរៀបចំពិធី
- កំណត់សមាសភាពចូលរួមពិធី តាមទីតាំងនីមួយៗ
- រៀបចំលិខិតអញ្ជើញភ្ញៀវជាតិ-អន្តរជាតិ ចូលរួមពិធីតាមព្រឹត្តិការណ៍កម្មវិធីគ្រោងទុក
- រៀបចំស្លាកជូនភ្ញៀវជាតិ-អន្តរជាតិ និងបណ្ណសម្គាល់រថយន្ត
- ប្រមែប្រមូលឯកសារប្រវត្តិសាស្ត្រយោធា សម្រាប់ពិពណ៌ក្នុងសារមន្ទីរសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ផលិតឯកសារ បណ្ណផ្ចិត និងបដា ជាភាសាខ្មែរ-អង់គ្លេស
- ចងក្រងឯកសារជាកាសែតវីដេអូ រក្សាទុកជាប្រវត្តិសាស្ត្រ
- រៀបចំឯកសារជំនួយស្មារតី និងសុន្ទរកថា ជូនថ្នាក់ដឹកនាំ សម្រាប់ពិធីនីមួយៗតាមកម្មវិធីគ្រោងទុក
- រៀបចំអាវុធ ឧបករណ៍ សម្ភារៈយោធបរិក្ខា ធ្វើជាកស្តុតាង
- សហការជាមួយបណ្តាញព័ត៌មាន ផ្សព្វផ្សាយព្រឹត្តិការណ៍ជូនសាធារណជនជាតិ-អន្តរជាតិ
- តាមដាន និងធ្វើប្រតិកម្មរហ័ស ជាមួយប្រព័ន្ធព័ត៌មានដែលចុះផ្សាយខុសពីការពិត
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលទិវានៃការចងចាំនៃដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រាយការណ៍ជូនប្រធានគណៈកម្មការ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការប្រគល់ជូន ។

**ខ.អនុគណៈកម្មការពិធីការ**

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | ឈិន កេតនា | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ និងអន្តរជាតិ | ប្រធាន |
| ២. ឯកឧត្តម | អិត សិលា | អគ្គលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣. ឧត្តមសេនីយ៍ឯក | ខៀវ ឆេន | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ | សមាជិកប្រចាំការ |
| ៤. លោកជំទាវ | សុខ ស៊ីថន | ជំនួយការសម្តេចតេជោ នាយករដ្ឋមន្ត្រី និងជាប្រធាន នាយកដ្ឋានពិធីការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឧត្តមសេនីយ៍ឯក | ប៉ាង ធារ៉ូ | អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន កពជ | សមាជិក |
| ៦. ឧត្តមសេនីយ៍ទោ | ងី វណ្ណនឹម | នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ | សមាជិក |
| ៧. វរសេនីយ៍ឯក | ជៀម វីរៈ | នាយរងការិយាល័យអនុព័ន្ធយោធាព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម | សមាជិក ។ |

❖ អនុគណៈកម្មការនេះមានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- រៀបចំទីកន្លែងគណៈអធិបតី និងពិធីការសម្រាប់តំណាងស្បជនជាតិ-អន្តរជាតិ
- រៀបចំបញ្ជីឈ្មោះភ្ញៀវជាតិ-អន្តរជាតិ ចូលរួមពិធីតាមទីតាំង និងកម្មវិធីជាក់ស្តែង
- រៀបចំពិធីការ និងបដិសណ្ឋារកិច្ចទទួលគណៈប្រតិភូ និងភ្ញៀវជាតិ-អន្តរជាតិ
- រៀបចំកម្មវិធី និងសកម្មភាពការងារតាមទីតាំងជាក់ស្តែងនៅក្នុងភូមិសាស្ត្រប្រទេសកម្ពុជា-វៀតណាម

- សហការជាមួយភាគីមិត្ត កំណត់សមាសភាពចូលរួម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការប្រគល់ជូន ។

**គ.អនុគណៈកម្មការធានា**

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | វង្សី វិស្សុត | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម | សួង ហេង | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣. ឯកឧត្តម | ហួត សារឹម | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤. នាយឧត្តមសេនីយ៍ | ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ កពជ | សមាជិកប្រចាំការ |
| ៥. លោក | ហេង រដ្ឋពិសិដ្ឋ | ប្រធាននាយកដ្ឋានផ្លូវ ថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦. លោក | គង់ កឿន | ប្រធាននាយកដ្ឋានផ្លូវជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧. លោក | វង្សី វិចិត្រ | អនុប្រធាននាយកដ្ឋានវិនិយោគ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. ឧត្តមសេនីយ៍ទោ | សឿន រឿត | នាយករង នាយកដ្ឋានវិស្វកម្ម កពជ | សមាជិក |
| ៩. ឧត្តមសេនីយ៍ទោ | អ៊ី តេនវិសេស | នាយករង នាយកដ្ឋានវិស្វកម្ម កពជ | សមាជិក ។ |

❖ អនុគណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- លើកគម្រោងថវិកា សម្រាប់ចំណាយទូទៅជូនប្រធានគណៈកម្មការ ដើម្បីពិនិត្យសម្រេច និងស្នើសុំកញ្ចប់ថវិកាពីរាជរដ្ឋាភិបាល
- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ ចំណូល-ចំណាយ ដើម្បីបម្រើដល់ដំណើរការរៀបចំប្រារព្ធពិធី
- រៀបចំការស្នាក់នៅ ហូបចុក និងធ្វើដំណើររបស់គណៈអធិបតី និងភ្ញៀវជាតិ-អន្តរជាតិ
- លើកផែនការតម្រូវការ មធ្យោបាយ រថយន្ត ក្រុមពេទ្យចល័ត សម្រាប់បម្រើឲ្យការប្រារព្ធពិធីជាក់ស្តែង
- រៀបចំផែនការ សកម្មភាព និងកម្មវិធីការងារលម្អិត
- ចុះសិក្សាភូមិសាស្ត្រ ត្រូវធ្វើដំណើរ និងរៀបចំពិធី
- ឈូសឆាយផ្លូវ និងទីតាំងសម្រាប់រៀបចំពិធីជាក់ស្តែង
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការប្រគល់ជូន ។

**ឃ.អនុគណៈកម្មការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

| | | | |
|---|---|---|---|
| ១. នាយឧត្តមសេនីយ៍ | សៅ សុខា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ប្រធាន |
| ២. នាយឧត្តមសេនីយ៍ | ដាំ វុទ្ធី | អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៣. ឯកឧត្តម | គន់ សុភា | អភិបាលរង នៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ៤. ឧត្តមសេនីយ៍ឯក | ភួង ស៊ីភិន | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥. ឧត្តមសេនីយ៍ទោ | ប៉ែន វ៉ុទ្ធ | ស្នងការនគរបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ៦. ឧត្តមសេនីយ៍ត្រី | ភិ សារិទ្ធ | មេបញ្ជាការកងរាជអាវុធហត្ថខេត្តត្បូងឃ្មុំ | សមាជិក ។ |

❖ អនុគណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- រៀបចំផែនការ ការពារសន្តិសុខ សុវត្ថិភាព របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងចរាចរណ៍ តាមទីតាំងរៀបចំពិធីនីមួយៗ



www.pheakdeylaw.com

- សហការជាមួយភាគីវៀតណាម រៀបចំផែនការ ការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងភូមិសាស្ត្រប្រទេសវៀតណាម
- ត្រៀមលក្ខណៈ និងមធ្យោបាយគ្រប់ផ្នែក សម្រាប់បម្រើការងារការពារសន្តិសុខ សណ្តាប់ធ្នាប់
- ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការប្រគល់ជូន ។

**ប្រការ៣.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់កញ្ចប់ថវិកាបស់រាជរដ្ឋាភិបាល និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន ។

**ប្រការ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងាររបស់ខ្លួន តាមការចាំបាច់ និងមានទីតាំងបំពេញការងារនៅទីស្តីការក្រសួងការពារជាតិ ។

អនុប្រធាន សមាជិកគណៈកម្មការ ប្រធាន អនុប្រធាន សមាជិកអនុគណៈកម្មការ និងលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៥.-**

គណៈកម្មការនេះ នឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

**ប្រការ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



៤

www.pheakdeylaw.com